ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស
លេខៈ...០៣៣.../...១៤...ពបក

ភ្នំពេញ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤

# សេចក្តីជូនដំណឹង

## សន្និសីទសារព័ត៌មាន ស្តីពីអំពើហិង្សាដែលបង្កឡើងដោយបេក្ខជនជាប់ឆ្នោត និងសកម្មជនគណបក្សសង្គ្រោះជាតិ នៅទីលានប្រជាធិបតេយ្យ

ឯកឧត្តម **ផៃ ស៊ីផាន** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាអនុប្រធានអង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស នឹងធ្វើសន្និសីទសារព័ត៌មាន ស្តីពីអំពើហឹង្សាដែលបង្កឡើងដោយបេក្ខជនជាប់ឆ្នោត និងសកម្មជនគណបក្សសង្គ្រោះជាតិ នៅទីលានប្រជាធិបតេយ្យ កាលពីព្រឹកថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០១៤។ អំពើហឹង្សានេះ បានបង្កឲ្យរងរបួសសន្តិសុខសណ្តាប់សាលាខ័ណ្ឌដូនពេញយ៉ាងហោចណាស់ចំនួន ៣៨នាក់ ក្នុងនោះ ២២នាក់ រងរបួសធ្ងន់ និង ៣នាក់ទៀត កំពុងសង្គ្រោះបន្ទាន់។

សន្និសីទសារព័ត៌មាននេះ នឹងប្រព្រឹត្តទៅនៅវេលាម៉ោង ១១.០០ព្រឹក នាទីស្តីការគណៈរដ្ឋមន្ត្រី វិមានមិត្តភាព អគារ A។

សូមអ្នកសារព័ត៌មានជាតិនិងអន្តរជាតិចូលរួមក្នុងសន្និសីទសារព័ត៌មាននេះ។៚

ចំពោះព័ត៌មានពិស្តារ សូមទាក់ទងអង្គភាពព័ត៌មាននិងប្រតិកម្មរហ័ស៖

- លេខទូរស័ព្ទ៖ ០១២ ៩០៦ ៥៦៣
- E-mail៖ pressocm@gmail.com